# សន្និបាតបូកសរុបលទ្ធផលការងារ
# ប្រចាំឆ្នាំ២០២៤ និង ទិសដៅអនុវត្តឆ្នាំ២០២៥

## ក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា អាជ្ញាធរទន្លេសាប

## លទ្ធផលការងារហិរញ្ញវត្ថុប្រចាំ២០២៤ និងទិសដៅអនុវត្តឆ្នាំ២០២៥

នាយកដ្ឋានហិរញ្ញវត្ថុ



# សេចក្តីផ្តើម

នាយកដ្ឋានហិរញ្ញវត្ថុ ជាសេនាធិការឱ្យក្រសួង ក្នុងការអនុវត្តមាត្រា៩ នៃអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម៖

- លើកគម្រោងថវិកាក្រសួង ធ្វើកម្មវិធីចំណាយ និងតាមដានរំលឹកពីការប្រតិបត្តិ
- សម្របសម្រួលជំពូកថវិកា និងរាល់ចំណាយរបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- ធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ គ្រឿងបន្លាស់សម្រាប់យានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង
- ទទួល និងបែងចែកបរិក្ខារ ជូនដល់បណ្តាអង្គភាពនានាក្រោមឱវាទក្រសួង
- កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និងគណនេយ្យរូបធាតុ
- គ្រប់គ្រងព័ត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ
- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តលទ្ធកម្មសាធារណៈ
- ប្រមូលចំណូលឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុបង់ចូលថវិការដ្ឋ

**នាយកដ្ឋានហិរញ្ញវត្ថុ មានការិយាល័យចំណុះចំនួន ៣ រួមមាន៖ (១).ការិយាល័យរដ្ឋបាល (២).ការិយាល័យហិរញ្ញកិច្ច និង(៣).ការិយាល័យគណនេយ្យ។**

# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤

ក្នុងឆ្នាំ២០២៤ នាយកដ្ឋានហិរញ្ញវត្ថុ បានអនុវត្តសកម្មភាព ដូចតទៅ៖

- បើកប្រាក់បៀវត្ស និងបេសកកម្មជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ តាមប្រព័ន្ធធនាគារទាន់ពេលវេលា
- រៀបចំកម្មវិធីចំណាយថ្នាក់ជាតិរបស់ក្រសួង
- បញ្ចូលផែនការចំណូល-ចំណាយសាច់ប្រាក់ឆ្នាំ២០២៤ នៅក្នុងប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ (CMS) របស់អគ្គនាយកដ្ឋានរតនាគារជាតិ ទាន់ពេលវេលា
- ផ្សព្វផ្សាយឯកសារថវិកា រួមមាន (១) *សៀវភៅផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៤-២០២៦* (២) *សៀវភៅគម្រោងផែនការថវិកាតាមកម្មវិធីស្នើឡើងសម្រាប់ឆ្នាំ២០២៤* (៣) *ផែនការលទ្ធកម្មប្រចាំឆ្នាំ ២០២៤* និង (៤) *ការគ្រប់គ្រងឆ្នាំ២០២៤* (ចំណាត់ថ្នាក់សេដ្ឋកិច្ច និងកម្មវិធី) លើគេហទំព័ររបស់ក្រសួង
- រៀបចំវេទិកាសាធារណៈ ស្តីពីការផ្សព្វផ្សាយថវិកាប្រចាំឆ្នាំ ២០២៤ របស់ក្រសួងធនធានទឹក និងឧតុនិយម នៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៤ ដោយមានសិក្ខាកាមចូលរួម ចំនួន ២១៦ រូប ក្នុងនោះស្ត្រី ចំនួន ៤៣ រូប

## ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤ (ត)

- រៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ២០២៥-២០២៧ និងគម្រោងថវិកាប្រចាំឆ្នាំ២០២៥ ដោយបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាន់ពេលវេលា
- រៀបចំលិខិតស្នើសុំធ្វើការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិពេញលេញជូនអង្គភាពថវិកាចំនួន ២ អង្គភាព គឺ អាជ្ញាធរទន្លេសាប និង គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សម្រាប់ការអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ២០២៥ និងប្រកាសអន្តរក្រសួងរវាងក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្ដីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា
- អនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម រវាងក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការអនុវត្តថវិកាកម្មវិធី/សមិទ្ធកម្មឆ្នាំ២០២៤
- រៀបចំឯកសារទូទាត់ចំណាយបន្ទុកបុគ្គលិក ទូទាត់ត្រង់ ទូទាត់រដ្ឋទេយ្យបុរេប្រទាន និងចំណាយផ្សេងៗ
- រៀបចំរបាយការណ៍ចំណាយប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស
- រៀបចំរបាយការណ៍សមិទ្ធកម្ម នៃការអនុវត្តថវិកាកម្មវិធីប្រចាំឆមាសទី១ និងប្រចាំឆ្នាំ ២០២៤

# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤ (ត)

- រៀបចំរបាយការណ៍លទ្ធកម្មប្រចាំត្រីមាស និងឆមាស
- រៀបចំរបាយការណ៍រដ្ឋទេយ្យ
- ដីចំនួន ៤កន្លែងដែលស្ថិតក្រោមទីស្តីការក្រសួងបានចុះបញ្ជីប័ណ្ណកម្មសិទ្ធិ
- រៀបចំសៀវភៅសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២៣ និងសៀវភៅតារាងប្រៀបធៀបកើនឡើង-ថយចុះ ទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២៣
- ធ្វើបច្ចុប្បន្នភាពទ្រព្យសម្បត្តិរដ្ឋដោយកត់ត្រាបញ្ចូលទៅក្នុងសៀវភៅបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់អង្គភាព នីមួយៗតាមប្រព័ន្ធSARMIS
- អនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Nontax Revenue Management Information System - NRMIS)

# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤ (ត)

នាយកដ្ឋានក៏បាន និងកំពុងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាកម្មវិធីអាទិភាពមួយក្នុងចំណោមកម្មវិធីកែទម្រង់អាទិភាពផ្សេងទៀតរបស់រាជរដ្ឋាភិបាល៖

❖ **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP)៖**

- រៀបចំផែនការសកម្មភាពលម្អិត (MAP), KPIs និងបានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ២០២៤
- បញ្ជូនមន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ ចូលរួមវគ្គបណ្តុះបណ្តាល "ជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង" នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០២៤ ដោយមានសិក្ខាកាមចូលរួម ចំនួន ៨ រូប ក្នុងនោះស្ត្រី ចំនួន ៤ រូប
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ លើសេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMM) របស់ក្រសួងធនធានទឹក និងឧតុនិយម នៅថ្ងៃទី ១៥ ដល់ ១៦ ខែ សីហា ឆ្នាំ២០២៤ ដោយមានសិក្ខាកាមចូលរួម ចំនួន ១៥៣ រូប ក្នុងនោះស្ត្រី ចំនួន ៥២ រូប

# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤ (ត)

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធនធានទឹក និងឧតុនិយម សូចនាករ និងរបាយការណ៍សមិទ្ធកម្ម និងសវនកម្មលើបច្ចេកវិទ្យាព័ត៌មានវិទ្យា នាថ្ងៃទី ២០ ដល់ ២១ ខែ វិច្ឆិកា ឆ្នាំ ២០២៤ ដោយមានសិក្ខាកាមចូលរួម ចំនួន ១៥០ រូប ក្នុងនោះស្ត្រីចំនួន ៥៩ រូប
- រៀបចំ និងបញ្ជូនសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រសួង (FMM) ទៅអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងផ្តល់យោបល់។

# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤ (ត)

❖ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)៖

- បញ្ចូល (ក) *ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៤-២០២៦* (ខ) *គម្រោងចំណាយប្រាក់បៀវត្សមន្ត្រីរាជការ* និង (គ) *គម្រោងចំណាយថវិកាប្រចាំឆ្នាំ២០២៤ ទៅក្នុងប្រព័ន្ធរៀបចំផែនការថវិកា* (BPS)
- កត់ត្រាមុខងារវិភាជន៍ថវិកា (BA) ក្នុងប្រព័ន្ធFMIS រួមមាន (ក) *ការព្យាករជួទេយ្យបុរេប្រទានដើមឆ្នាំ២០២៤* និង (ខ) *និយ័តកម្មផ្ទៃក្នុងសម្រាប់ឆ្នាំ២០២៤*
- បញ្ចូល និងកត់ត្រាមុខងារការទិញ (PO) និងមុខងារលទ្ធកម្មពេញលេញ (PR)
- បញ្ចូលអាណត្តិទូទាត់ត្រង់ ចំណាយបន្ទុកបុគ្គលិក ចំណាយរជួទេយ្យបុរេប្រទាន និងចំណាយផ្សេងៗនៅក្នុងមុខងារគណនីត្រូវសង (AP)
- កត់ត្រាចំណូលនៅក្នុងមុខងារគណនីត្រូវទារ (AR)។

# ១. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤ (ត)

## ដ្យាក្រាមចំណាយថវិកាឆ្នាំ២០២៤ របស់ក្រសួងធនធានទឹក និងឧតុនិយម



## ២. បញ្ហាប្រឈម

ក. យោងតាមសារាចរលេខ ០០៤ សហវ.ស.រ.អថ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្ដីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាថ្នាក់ជាតិ សម្រាប់អនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ក្រសួងបានរងវិចារណកម្មដោយត្រូវបានកាត់ព្យួរឥណទានចន្លោះ ១៥% ទៅ ២៥% នៃឥណទានសរុប ជាហេតុធ្វើឱ្យឥណទានរបស់ក្រសួងមានការថយចុះ

ខ. របត់នៃការវិវត្តការអនុវត្តថវិកាកម្មវិធី ទៅអនុវត្តថវិកាសមិទ្ធកម្ម ដែលផ្ដោតលើការកំណត់ និងសម្រួលសូចនាករសមិទ្ធកម្ម និងគោលដៅសូចនាករសមិទ្ធកម្មរបស់អង្គភាពថវិកា ឱ្យកាន់តែច្បាស់លាស់ ងាយយល់ និងអាចសម្រេចបាន

# ៣. សេចក្ដីសន្និដ្ឋាន

- ថ្នាក់ដឹកនាំ និងមន្ត្រីនាយកដ្ឋាន បានខិតខំប្រឹងប្រែងបំពេញភារកិច្ចទៅតាមតួនាទី និងសមត្ថភាពរបស់ខ្លួន ដោយទទួលបានលទ្ធផលគួរជាទីកត់សម្គាល់ បើទោះបីជាមានបញ្ហាប្រឈមមួយចំនួនដែលត្រូវពុះពារ

- ថវិកាឆ្នាំ២០២៤ ជាឧបករណ៍គោលនយោបាយដ៏សំខាន់ និងជួយគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍលើវិស័យធនធានទឹក រយៈពេល ៥ ឆ្នាំ (ឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨) របស់ក្រសួង

- តាមរយៈការគាំទ្រពីនាយកដ្ឋាន ក្រសួងបានស្ដារឡើងវិញ ជួសជុល សាងសង់ និងថែទាំប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាព ដែលមានទិសដៅរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលនយោបាយ "**ការគ្រប់គ្រង អភិវឌ្ឍន៍ និងអភិរក្សធនធានទឹក ប្រកបដោយប្រសិទ្ធភាពខ្ពស់ សមធម៌ និងនិរន្តរភាព**" ក៏ដូចជាគោលដៅសូចនាករសំខាន់ៗរបស់ក្រសួង។

# ៤. ទិសដៅអនុវត្តឆ្នាំ២០២៥

ក. អនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម រវាងក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុវត្តថវិកាកម្មវិធី/សមិទ្ធកម្មឆ្នាំ២០២៥

ខ. គាំទ្រ អាជ្ញាធរទន្លេសាប និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដើម្បីអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ២០២៥

គ. ដាក់ឱ្យអនុវត្ត គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងធនធានទឹក និងឧតុនិយម នៅឆ្នាំ២០២៥

ឃ. រៀបចំអង្គភាពដែលជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញទាំង២ (អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស) ឱ្យទៅជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅឆ្នាំបន្តបន្ទាប់

ង. ជំរុញនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួង ឱ្យក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ

ច. គ្រោងបញ្ជូនមន្ត្រីចំនួន ១៨ រូប ចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លី នៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០២៥

ឆ. បន្តគាំទ្រ និងចូលរួមយ៉ាងសកម្មក្នុងការអនុវត្តសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាការកំណត់ និងតម្រូវការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ជ. គ្រោងនឹងអនុវត្ត FMIS ពេញលេញ ទៅតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ៤. ទិសដៅអនុវត្តឆ្នាំ២០២៥ (ត)

ក្នុងឆ្នាំ២០២៥ ក្រសួងធនធានទឹក និងឧតុនិយម មានរចនាសម្ព័ន្ធកម្មវិធី និងឥណទានថវិកាដូចតទៅ៖

❖ រចនាសម្ព័ន្ធកម្មវិធីឆ្នាំ២០២៥ របស់ក្រសួងធនធានទឹក និងឧតុនិយម



# ៤. ទិសដៅអនុវត្តឆ្នាំ២០២៥ (ត)

❖ គោលបំណងកម្មវិធីទាំង៥ របស់ក្រសួងធនធានទឹក និងឧតុនិយម

| កម្មវិធី | | គោលបំណងកម្មវិធី |
|---|---|---|
| កម្មវិធីទី១៖ | ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យធនធានទឹក | លើកកម្ពស់ការគ្រប់គ្រង ប្រើប្រាស់ បែងចែកទឹក ប្រកបដោយប្រសិទ្ធភាព សមធម៌ និងនិរន្តរភាព តាមរយៈការស្តារឡើងវិញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាពសាស្ត្រគ្រប់ប្រភេទ |
| កម្មវិធីទី២៖ | ការគ្រប់គ្រង និងកាត់បន្ថយទឹកជំនន់ គ្រោះរាំងស្ងួត និងទឹកប្រៃ | ការពារ និងកាត់បន្ថយផលប៉ះពាល់ពីគ្រោះធម្មជាតិតាមរយៈ ការសិក្សាស្រាវជ្រាវ និងសាងសង់ទំនប់អាងទឹក ទំនប់ការពារ ប្រឡាយដោះទឹក ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ និងការចុះអន្តរាគមន៍សង្គ្រោះដំណាំស្រូវ វស្សា និងស្រូវប្រាំង ពេលជួបការខ្វះខាតទឹក និងគ្រោះរាំងស្ងួត |
| កម្មវិធីទី៣៖ | ការការពារ និងការអភិរក្សវិស័យធនធានទឹក | លើកកម្ពស់ការគ្រប់គ្រង និងអភិរក្សធនធានទឹក ប្រកបដោយនិរន្តរភាព តាមរយៈការរៀបចំ តាក់តែងអនុក្រឹត្យ ការរៀបចំ និងកែលម្អលិខិតបទដ្ឋាន និងនីតិវិធីនានាដែលពាក់ព័ន្ធ ដើម្បីធ្វើការផ្សព្វផ្សាយ និងអនុវត្ត |
| កម្មវិធីទី៤៖ | ពង្រឹងការគ្រប់គ្រង នវានុវត្តន៍លើព័ត៌មាន និងទិន្នន័យធនធានទឹក និងឧតុនិយម | -ពង្រឹង និងពង្រីកការព្យាករណ៍ ការផ្សព្វផ្សាយព័ត៌មានជលសាស្ត្រនិងឧតុនិយម ស្តីពីគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតប្រកបដោយប្រសិទ្ធភាព និងស័ក្តសិទ្ធភាព តាមរយៈការពង្រឹង និងពង្រីកបន្ថែមនូវប្រព័ន្ធជលសាស្ត្រ និងឧតុនិយម<br>-រៀបចំចងក្រងបញ្ជីសារពើភ័ណ្ឌប្រព័ន្ធជាពសាស្ត្រ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យស្ថិតិរបស់ក្រសួងលើគ្រប់ផ្នែកទាំងអស់ |
| កម្មវិធីទី៥៖ | ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ | បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន តាមរយៈការផ្តល់សេវាគាំទ្រនិងពង្រឹងសមត្ថភាព បណ្តុះបណ្តាល និងអប់រំសម្រាប់ការអភិវឌ្ឍន៍វិស័យធនធានទឹក និងឧតុនិយម ប្រកបដោយនិរន្តរភាព |

# ៤. ទិសដៅអនុវត្តឆ្នាំ២០២៥ (ត)

❖ អង្គភាពថវិការបស់ក្រសួងធនធានទឹក និងឧតុនិយម

ក្រសួងធនធានទឹក និងឧតុនិយម បានបង្កើតអង្គភាពថវិកាចំនួន ២៩ ក្នុងនោះ៖

ក. រដ្ឋបាលថ្នាក់កណ្តាល មានអង្គភាពថវិកា ចំនួន ៤ ៖

១. អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល

២. អគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស

៣. គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

៤. អាជ្ញាធរទន្លេសាប

ខ. ថ្នាក់មន្ទីរជំនាញរាជធានី-ខេត្ត មានអង្គភាពថវិកាចំនួន ២៥ (មន្ទីរធនធានទឹក និងឧតុនិយម ទាំង២៥ រាជធានី-ខេត្ត)។

# ៤. ទិសដៅអនុវត្តឆ្នាំ២០២៥ (ត)

❖ ឥណទានកម្មវិធីឆ្នាំ២០២៥ (ឥណទានអនុម័ត)

ឯកតា ៖ លានរៀល

| បរិយាយ | សរុបរួម | កម្មវិធីទី១ | កម្មវិធីទី២ | កម្មវិធីទី៣ | កម្មវិធីទី៤ | កម្មវិធីទី៥ |
|---|---|---|---|---|---|---|
| **សរុបតាមកម្មវិធី (I+II)** | 311.552,0 | 241.593,6 | 3.327,0 | 4.378,2 | 2.845,8 | 59.407,4 |
| **I. ថ្នាក់កណ្តាល** | 268.027,0 | 230.508,6 | 2.311,0 | 4.378,2 | 2.684,8 | 28.144,4 |
| ក. ចំណាយចរន្ត | 148.027,0 | 110.508,6 | 2.311,0 | 4.378,2 | 2.684,8 | 28.144,4 |
| ខ. ចំណាយមូលធន | 120.000,0 | 120.000,0 | - | - | - | - |
| **II. ថ្នាក់រាជធានី-ខេត្ត** | 43.525,0 | 11.085,0 | 1.016,0 | - | 161,0 | 31.263,0 |
| ក. ចំណាយចរន្ត | 43.525,0 | 11.085,0 | 1.016,0 | - | 161,0 | 31.263,0 |
| ខ. ចំណាយមូលធន | - | - | - | - | - | - |

# ៤. ទិសដៅអនុវត្តឆ្នាំ២០២៥ (ត)

## រូបភាពទី១ ៖ ដ្យាក្រាមគម្រោងចំណាយសម្រាប់ឆ្នាំ២០២៥




| ល.រ | បរិយាយ | ឥណទានឆ្នាំ២០២៥ (លានរៀល) | % |
|---|---|---|---|
| 1 | ចំណាយបន្ទុកបុគ្គលិក | 41,408.0 | 13.3% |
| 2 | ការថែទាំប្រព័ន្ធធារាសាស្ត្រ | 113,423.6 | 36.4% |
| 3 | ការសាងសង់ ស្ដារ និងជួសជុលប្រព័ន្ធធារាសាស្ត្រ | 120,000.0 | 38.5% |
| 4 | ចំណាយផ្សេងៗ | 36,720.4 | 11.8% |
| | **សរុបរួម** | 311,552.0 | 100.0% |

# ៤. ទិសដៅអនុវត្តឆ្នាំ២០២៥ (ត)

## រូបភាពទី២ ៖ ការប្រៀបធៀបឥណទានឆ្នាំ២០២៥ និងឥណទានឆ្នាំ២០២៤

ឯកតា៖ លានរៀល

| កម្មវិធី | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២៤ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២៥ | ធៀបច្ប. ឆ្នាំ២០២៤ | |
|---|---|---|---|---|
| | | | កើន-ថយ | % |
| | ១ | ២ | ៣=២-១ | ៤=២/១ |
| កម្មវិធីទី១ | 231.554,0 | 241.593,6 | 10.039,6 | 104,3% |
| កម្មវិធីទី២ | 3.603,0 | 3.327,0 | -276,0 | 92,3% |
| កម្មវិធីទី៣ | 2.261,0 | 4.378,2 | 2.117,2 | 193,6% |
| កម្មវិធីទី៤ | 3.087,9 | 2.845,8 | -242,1 | 92,2% |
| កម្មវិធីទី៥ | 65.538,1 | 59.407,4 | -6.130,7 | 90,6% |
| សរុបរួម | 306.044,0 | 311.552,0 | 5.508,0 | 101,8% |

ឥណទានឆ្នាំ២០២៥ កើនឡើង ១,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤




*កំណត់សម្គាល់៖ យោងសារាចរលេខ ០០៤ សហវ.ស.រ.អថ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាថ្នាក់ជាតិ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ក្រសួងធនធានទឹក និងឧតុនិយម បានវេងវិចារណកម្មសរុបចំនួន ១៩.០៧៨,៩ លានរៀល (ក្នុងនោះចំណាយមូលធនចំនួន ១៨.០០០,០ លានរៀល និងចំណាយចរន្តចំនួន ១.០៧៨,៩ លានរៀល)។

សូមអរគុណ

THANK YOU

